# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)
# គម្រោងបញ្ចប់ផែនការ
# កំណែលើកទី៤
# ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥


**សេចក្តីសង្ខេប** .......... 2

I. **សេចក្តីផ្តើម** .......... 3

II. **វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស** .......... 7

III. **ផែនការបញ្ចប់ការស៊ើបអង្កេត** .......... 8

IV. **ផែនការបញ្ចប់សវនាការ** .......... 11

ក. សំណុំរឿង០០២/០២ .......... 12

ខ. បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុក្នុងសំណុំរឿង០០២ .......... 13

គ. សំណុំរឿង០០៣ និង សំណុំរឿង០០៤ .......... 14

V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ** .......... 14

ក. សំណុំរឿង០០២/០១ .......... 14

ខ. សំណុំរឿង ០០២/០២ .......... 16

VI. **សេចក្តីសន្និដ្ឋាន** .......... 17

## សេចក្តីសង្ខេប

គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានរៀបចំឡើងនៅខែមីនា ឆ្នាំ២០១៤ ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ការិយាល័យរដ្ឋបាល ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាបច្ចុប្បន្នភាពប្រចាំត្រីមាសទី៤ នៃគម្រោងបញ្ចប់ផែនការដែលផុតនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥។

ចាប់តាំងពីត្រីមាសចុងក្រោយនៃការបញ្ចប់ផែនការនេះ អង្គជំនុំជម្រះវិសាមញ្ញបានឈានដល់ដំណាក់កាលពិសេសមួយថែមទៀត នោះគឺ ការចាប់ផ្តើមសវនាការលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥។ មានការរីកចម្រើននៅក្នុងសំណុំរឿង ០០៣ ដោយ មាស មុត ត្រូវបានចោទប្រកាន់ដោយកំបាំងមុខ ចំណែកក្នុងសំណុំរឿង ០០៤ វិញ អ៊ឹម ចែម ត្រូវបានចោទប្រកាន់ដោយកំបាំងមុខ ហើយ អោ អាន ត្រូវបានចោទប្រកាន់ដោយផ្ទាល់។

លំហូរនៃគម្រោងបញ្ចប់ផែនការនេះត្រូវបានធ្វើបច្ចុប្បន្នភាព ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពនៃដំណើរការនីតិវិធីតុលាការគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥។ តារាងកំណត់ពេលវេលាសម្រាប់សំណុំរឿង ០០៣ និង ០០៤ ត្រូវបានកែប្រែ ផ្អែកតាមការរីកចម្រើននៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ។ មានកត្តាខាងក្នុង និងខាងក្រៅមួយចំនួន ដូចរៀបរាប់លម្អិតនៅក្នុងគម្រោងនេះ បានតម្រូវឱ្យមានការបន្ថែមរយៈពេលលើតារាងកំណត់ពេលវេលាសម្រាប់សំណុំរឿងទាំងអស់នេះ។

## I. សេចក្តីផ្តើម

១. អង្គជំនុំជ្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានចាប់ផ្តើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរការពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អាណត្តិនៃអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្តី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”[1]។ នៅក្នុងរបាយការណ៍មួយ ដែលបានដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិនៅខែមីនា ឆ្នាំ២០០៣ អគ្គលេខាធិការ ដំបូងឡើយបានបង្ហាញថា អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ មានរយៈពេលបីឆ្នាំ ដើម្បីបញ្ចប់ការជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលទាំងអស់ “នៅពេលដែលការិយាល័យរបស់សហព្រះរាជអាជ្ញា បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន”[2]។ តារាងកំណត់ពេលវេលាត្រូវបានកែប្រែចាប់តាំងពីពេលនោះមក ហើយអគ្គលេខាធិការបានជូនដំណឹងជាផ្លូវការដល់មហាសន្និបាតអង្គការសហប្រជាជាតិនៅខែតុលា ឆ្នាំ២០១៣ ថា តារាងកំណត់ពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញ “មានគម្រោងសកម្មភាពតុលាការរហូតដល់ឆ្នាំ២០១៨ និងអាចបន្តហួសពីពេលវេលាកំណត់នេះទៅទៀត”[3]។

២. គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយ អ.វ.ត.ក. ក្នុងបរិបទនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/68/247B ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់ អ.វ.ត.ក. ឱ្យរៀបចំយុទ្ធសាស្ត្របញ្ចប់ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ[4]។ ឯកសារនេះធ្វើឡើងដោយ អ.វ.ត.ក. ដោយមានការពិគ្រោះយោបល់តាមរយៈ ការិយាល័យរដ្ឋបាលជាមួយ ចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អ.វ.ត.ក. គិតទុកជាមុនថា នៅពេលខាងមុខ ខ្លួននឹងធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះគឺជាកំណែលើកទី៤ ប្រចាំត្រីមាសនៃគម្រោងបញ្ចប់ផែនការ ហើយបានបញ្ចូលនូវការកែតម្រូវដោយផ្អែកលើការវិវត្តនៃដំណើរការនីតិវិធីតាមផ្លូវតុលាការ ដែលកំពុងប្រព្រឹត្តទៅក្នុងរវាងថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែ មីនា ឆ្នាំ២០១៥។

៣. ឯកសារនេះផ្តោតជាពិសេសលើការវិវត្តន៍នាពេលថ្មីៗនេះ នៅក្នុងសំណុំរឿងទាំងបី ដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខ អ.វ.ត.ក. និងផ្តល់នូវព័ត៌មានអំពីប្រភេទនៃរឿងក្តី ព្រមទាំងស្ថានភាពនៃសំណុំរឿងទាំងនោះ ព្រមទាំងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការទាក់ទិននឹងសំណុំរឿងកំពុងរង់ចាំបច្ចុប្បន្ននៅចំពោះមុខ អ.វ.ត.ក. អាចនឹងបញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។

៤. អង្គជំនុំជម្រះវិសាមញ្ញបានបញ្ចប់ជាស្ថាពរនូវកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានចេញសាលដីការបស់ខ្លួនលើបណ្តឹងសាទុក្ខ កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២។ កាំង ហ្គេកអ៊ាវ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត

---

[1] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[2] របាយការណ៍របស់អគ្គលេខាធិការស្តីពីការជំនុំជម្រះខ្មែរក្រហម ឯកសារ A/57/769 កថាខណ្ឌ ៥៦។

[3] សំណើសុំឧបត្ថមធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឯកសារ A/68/532 កថាខណ្ឌ ៣៨។

[4] នៅក្នុងសេចក្តីសម្រេចដដែលនោះ មហាសន្និបាត អ.ស.ប. បានស្នើឱ្យមាន “ការពិនិត្យយ៉ាងម៉ត់ចត់ទៅលើការផ្តល់ហិរញ្ញប្បទានសម្រាប់ អ.វ.ត.ក នៅពេលអនាគតសម្រាប់ឆ្នាំ ២០១៥ និងឆ្នាំខាងមុខទៀត”។ សូមមើលសេចក្តីសម្រេចលេខ A/RES/68/247B ដែលអនុម័តដោយមហាសន្និបាត អ.ស.ប. នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៤៖ “កម្មវត្ថុពិសេសនានាទាក់ទិននឹងថវិកាសម្រាប់កម្មវិធីរយៈពេល២ឆ្នាំម្តង ២០១៤-២០១៥” ខ, I, កថាខណ្ឌទី៨។

និងត្រូវបានបញ្ជូនទៅពន្ធនាគារខេត្តកណ្ដាល កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ដើម្បីអនុវត្តទោសដែលនៅសល់។

៥. បច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង០០២ ដែលជាការជំនុំជម្រះរួមលើ ខៀវ សំផន និង នួន ជា។ ជនជាប់ចោទទីបី ឈ្មោះ អៀង សារី បានទទួលមរណភាពកាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ហើយកិច្ចដំណើរការនីតិវិធីលើរូបគាត់ ត្រូវបានបញ្ចប់នៅថ្ងៃនោះផងដែរ។ ជនជាប់ចោទទីបួន ឈ្មោះ អៀង ធីរិទ្ធ ត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមនៅក្នុងសវនាការ ដោយសារតែស្ថានភាពជំងឺវង្វេងស្មារតីកាន់តែធ្ងន់ធ្ងរ ហើយកិច្ចនីតិវិធីលើរូបគាត់បច្ចុប្បន្ននេះត្រូវបានព្យួរ តាមរយៈការផ្អាកកិច្ចនីតិវិធីជាផ្លូវការ គាត់នៅតែស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការដដែល គាត់មិនត្រូវបានអនុញ្ញាតឲ្យចាកចេញពីប្រទេសកម្ពុជា ដោយគ្មានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង គាត់មិនអាចផ្លាស់ប្ដូរអាសយដ្ឋានស្នាក់នៅដោយមិនជូនដំណឹងជាមុននោះទេ ហើយអាណាព្យាបាលស្របច្បាប់របស់គាត់ ត្រូវផ្ដល់របាយការណ៍ប្រចាំខែ ដើម្បីបញ្ជាក់អំពីការអនុវត្តលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ។ អៀង ធីរិទ្ធ ក៏ត្រូវទទួលបានការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រពីរដងក្នុងមួយឆ្នាំ ដើម្បីវាយតម្លៃថាតើមានការប្រែប្រួលណាមួយ ទៅលើសមត្ថភាពបញ្ញាស្មារតី ដែលអាចប៉ះពាល់ដល់សម្បទារបស់គាត់ក្នុងការចូលរួមសវនាការផងដែរ។

៦. មកដល់ពេលនេះ អង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុងសំណុំរឿង០០២ ទៅជាសវនាការតូចៗ ចំនួនពីរ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមនៅក្នុងសវនាការដំណាក់កាលទីមួយ ដែល អ.វ.ត.ក. កំណត់ឈ្មោះសំណុំរឿងថា សំណុំរឿង០០២/០១ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤។ ខៀវ សំផន និង នួន ជា ត្រូវបានរកឃើញថាមានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៧៧ និង ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។ ទាំង នួន ជា និង ខៀវ សំផន បានដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១។ សហព្រះរាជអាជ្ញាក៏បានដាក់បណ្ដឹងសាទុក្ខ កម្រិតត្រឹមតែស្នើសុំសេចក្ដីប្រកាស ជាប្រយោជន៍ទៅលើការអនុវត្តទម្រង់ទូលាយបំផុតនៃសហឧក្រិដ្ឋកម្មរួម ដែលហៅថា JCE III ថាជាទម្រង់ទទួលខុសត្រូវមួយនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។

៧. ការជំនុំជម្រះទីពីរកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ ដែល អ.វ.ត.ក. ដាក់ឈ្មោះថា សំណុំរឿង ០០២/០២ គឺផ្ដោតលើជម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ ប្រឆាំងនឹងជនជាប់ចោទទាំងពីរនាក់ដែលនៅសល់។ អង្គជំនុំជម្រះសាលាដំបូងបានណែនាំថា ប្រធានបទសវនាការចាប់ផ្ដើមជាមួយនឹងបទចោទប្រកាន់ទាក់ទងទៅនឹងសហករណ៍ត្រាំកក់ រួមមានការប្រព្រឹត្តិលើពុទ្ធសាសនិក និងមន្ទីរសន្តិសុខក្រាំងតាចាន់ដែលពាក់ព័ន្ធ ដែលបន្ទាប់ពីនោះ ការជំនុំជម្រះនឹងដោះស្រាយការចោទប្រកាន់ ទាក់ទងនឹងការដ្ឋានដាក់លាក់ចំនួនបី។ បន្ទាប់មក សវនាការនឹងពិចារណាលើការប្រព្រឹត្តិលើក្រុមគោលដៅ (ចាម និងវៀតណាម) បន្តមកទៀតគឺមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង បទបញ្ញាស្ដីពីការរៀបអាពាហ៍ពិពាហ៍ លក្ខណៈនៃជម្លោះប្រដាប់អាវុធ និងតួនាទីរបស់ជនជាប់ចោទ។ សវនាការលើអង្គសេចក្ដីនៅក្នុងការជំនុំជម្រះក្ដីនេះ បានចាប់ផ្ដើមនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ជាមួយនឹងសេចក្ដីសន្និដ្ឋានចោទប្រកាន់ បន្ទាប់មកក៏មានពហិការចំនួន ៣ ខែទៅលើកិច្ចនីតិវិធី ពីសំណាក់ក្រុមមេធាវីការពារក្ដី។ ចាប់តាំងពីពេលនោះមក អង្គជំនុំជម្រះបានចាត់វិធានការនានាដើម្បីកុំឲ្យមានស្ថានភាពដូចនេះកើតឡើងដដែលៗ ដែលវិធានការទាំងនោះរួមមានការចាត់តាំងមេធាវីប្រចាំការ ដើម្បីទទួលការងារតំណាងកូនក្ដីនៅក្នុងករណីដែលមេធាវីការពារក្ដីបច្ចុប្បន្នបដិសេធមិនចូលរួមនៅថ្ងៃអនាគត ដោយបានបញ្ជាក់ថាក្រុមមេធាវីការពារក្ដីមានធនធានគ្រប់គ្រាន់ និង ដោយនិយាយយោងទៅដល់ការប្រព្រឹត្តិរបស់ក្រុមមេធាវីការពារក្ដីមួយក្រុម ដែលអាចទទួលនូវនីតិវិធីខាងវិន័យ។

៨. សវនាការលើភស្តុតាងក្នុងសំណុំរឿង០០២/០២ បានចាប់ផ្ដើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥។ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានស្ដាប់សក្ខីកម្មសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី

ចំនួន ១៩ នាក់ និងអ្នកជំនាញម្នាក់ លើប្រធានបទសវនាការលើកទីមួយ។ បន្ថែមលើសាក្សីមួយចំនួនបន្តទៀត លើប្រធានបទនេះ អង្គជំនុំជម្រះបានរៀបចំកាលវិភាគសវនាការស្តីពីព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធទៅនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសវនាការបង្ហាញឯកសារសំខាន់ៗ។ អង្គជំនុំជម្រះបានជ្រើសរើសសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ការដ្ឋានទំនប់ ១ មករា ដែលសវនាការអំពីការដ្ឋាននេះគ្រោងចាប់ផ្តើមក្នុងខែឧសភា ឆ្នាំ២០១៥។ អង្គជំនុំជម្រះក៏កំពុងធ្វើការត្រួតពិនិត្យបញ្ជីឈ្មោះបុគ្គលដែលត្រូវស្តាប់សក្ខីកម្ម ទាក់ទងជាមួយនឹងប្រធានបទសវនាការបន្ទាប់ ហើយអង្គជំនុំជម្រះកំពុងវាយតម្លៃភាពអាចទទួលយកបាននៃឯកសារ ដែលបានស្នើឡើងដោយភាគីថាពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធី។

៩. សំណុំរឿង ០០៣ និង ០០៤ កំពុងតែស្ថិតក្នុងដំណាក់កាលស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កំពុងតែស៊ើបអង្កេតយ៉ាងសកម្មទៅលើសំណុំរឿងទាំងនេះ ដែលពាក់ព័ន្ធនឹងការចោទប្រកាន់ជនត្រូវចោទ ៣ នាក់ និងជនសង្ស័យ ២ នាក់។ មានការបន្តវិកចម្រើនជាច្រើនទៅលើសំណុំរឿងទាំងពីរនេះនៅក្នុងអំឡុងត្រីមាសទី១ ឆ្នាំ២០១៥។ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានធ្វើការចោទប្រកាន់កំបាំងមុខទៅលើ មាស មុត ក្នុងសំណុំរឿង ០០៣ និង អ៊ឹម ចែម ក្នុងសំណុំរឿង ០០៤។ នៅថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៥ ជនសង្ស័យទីពីរក្នុងសំណុំរឿង ០០៤ ឈ្មោះ អោ អាន ក៏ត្រូវបានចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិផងដែរ និងបានបង្ហាញខ្លួនផ្ទាល់ សម្រាប់ការបង្ហាញខ្លួនលើកដំបូង។ អត្តសញ្ញាណជនសង្ស័យពីរទៀតដែលនៅសល់ គឺត្រូវរក្សាជាការសម្ងាត់។

១០. យោងតាមស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន មានការបន្តរំពឹងថា សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ អាចនឹងចេញនៅត្រីមាសទី៤ នៃឆ្នាំ២០១៥ ហើយសេចក្តីសម្រេចមួយ ក្នុងទម្រង់ជាដីកាដំណោះស្រាយ ថាតើជនសង្ស័យណាម្នាក់នឹងត្រូវចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះ ឬយ៉ាងណានោះ នឹងចេញនៅត្រីមាសទី៣ នៃឆ្នាំ២០១៦។

១១. ដោយហេតុថាមានការខុសប្លែកគ្នានៃស្ថានភាពស៊ើបអង្កេតប្រឆាំងនឹងចុងចោទទាំងបីនាក់ ក្នុងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កំពុងពិចារណាលើជម្រើសចំនួន២៖ ក) សំណុំរឿង០០៤ អាចនឹងត្រូវបំបែក ដែលក្នុងករណីនេះ សេចក្តីជូនដំណឹងចំនួន២ អំពីការបញ្ចប់កិច្ចស៊ើបសួរអាចនឹងចេញនៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៥ ហើយសេចក្តីជូនដំណឹងទី៣ នឹងចេញនៅត្រីមាសទី១ ឆ្នាំ២០១៦ ខ) ជម្រើសម្យ៉ាងទៀត សំណុំរឿង០០៤ អាចស្ថិតនៅក្នុងទម្រង់ដដែល ដែលក្នុងករណីនេះ កិច្ចស៊ើបសួរអាចបញ្ចប់នៅត្រឹមត្រីមាសទី១ ឆ្នាំ២០១៦។ ប្រសិនបើសំណុំរឿង០០៤ ត្រូវបានបំបែកទៅជាកិច្ចនីតិវិធីដាច់ដោយឡែកពីគ្នា គឺមានការប៉ាន់ស្មានថា ដីកាដំណោះស្រាយអាចចេញនៅក្នុងត្រីមាសទី១ ត្រីមាសទី៣ និងត្រីមាសទី៤ ឆ្នាំ២០១៦។ ប្រសិនបើសំណុំរឿង០០៤ មិនត្រូវបានបំបែក មានការប៉ាន់ស្មានថាសេចក្តីសម្រេចមួយ ក្នុងទម្រង់ជាដីកាដំណោះស្រាយ ថាតើនឹងត្រូវចោទប្រកាន់ ហើយបញ្ជូនទៅជម្រះចំពោះចុងចោទណាមួយ (ឬចុងចោទណាខ្លះ) នឹងចេញនៅត្រីមាសទី៤ ឆ្នាំ២០១៦។

១២. សហព្រះរាជអាជ្ញា បានលើកឡើងជាសាធារណៈថា បន្ទាប់ពីសំណុំរឿង០០៣ និង០០៤[5] នឹងលែងមានសំណុំរឿងបន្ថែមទៀតហើយ។ ចំនួនសំណុំរឿងដែលមានបច្ចុប្បន្ន គឺជាចំនួនសំណុំរឿងសរុបដែលនឹងត្រូវដោះស្រាយដោយ អ.វ.ត.ក.។

---

[5] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី - ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីចំនួនពីរ ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int Co Prosecutor 8 Sep_2009_(Eng).pdf)

។ សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១២ (www.eccc.gov.kh/sites/default/files/media/ECCC%20OCP%205%20June%202012%20En.pdf) និងសេចក្តីប្រកាស

១៣. តាមរយៈការវិវត្តន៍ក្នុងត្រីមាសចុងក្រោយនេះ គម្រោងបញ្ចប់ផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញ មានគ្រោងការសំខាន់ចំនួន ១៤ សម្រាប់សំណុំរឿងចំនួនបី ដែលអង្គជំនុំជម្រះនានាបានទទួល។ គ្រោងការសំខាន់ដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២ និង[6] ការព្យាករណ៍ ដែលបន្តពាក់ព័ន្ធគឺ៖

(i) ពេលវេលាកំណត់នៃការដាក់ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១ (នៅត្រីមាសទី២ ឆ្នាំ២០១៥)

(ii) សវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ (ត្រឹមត្រីមាសទី២ ឆ្នាំ២០១៥)

(iii) ការចេញសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ (ត្រីមាសទីមួយ ឆ្នាំ២០១៦)

(iv) ការបញ្ចប់សវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង០០២/០២ (ត្រឹមត្រីមាសទីបី ឆ្នាំ២០១៦)

(v) សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបួន ឆ្នាំ២០១៦)

(vi) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបី ឆ្នាំ២០១៧)

(vii) ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបួន ឆ្នាំ២០១៧) និង

(viii) ការចេញសាលដីកានៅក្នុងសំណុំរឿង០០២/០២ ប្រសិនបើមាន (ត្រីមាសទីពីរ ឆ្នាំ២០១៩)។

១៤. នៅក្នុងសំណុំរឿង ០០៣ និង ០០៤ គ្រោងការដាច់ដោយឡែក ត្រូវបានកំណត់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលនៅសេសសល់ ហើយក្នុងករណីមានការចោទប្រកាន់នោះ នឹងមានគ្រោងការបន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះ និងបណ្តឹងសាទុក្ខ[7]។ គ្រោងការសំខាន់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលបន្តនៅសេសសល់ គឺ៖

(ix) សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ (ត្រីមាសទី៤ ឆ្នាំ២០១៥)

(x) សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤ (ត្រីមាសទី៤ ឆ្នាំ២០១៥ និង/ឬ ត្រីមាសទី១ ឆ្នាំ២០១៦ អាស្រ័យទៅលើការបំបែកកិច្ចនីតិវិធីណាមួយ)។

(xi) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ជាមួយនឹងសេចក្តីសម្រេចថាតើបញ្ជូនរឿងទៅជំនុំជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី៣ ឆ្នាំ២០១៦)។

(xii) ការចេញដីកាដំណោះស្រាយ១ (ច្រើន) ក្នុងសំណុំរឿង០០៤ ជាមួយនឹងសេចក្តីសម្រេចថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី (អាស្រ័យលើ ថាតើសំណុំរឿងនឹងត្រូវបំបែក ឬអត់ នៅត្រីមាស១ ទី៣ ឬទី៤ ឆ្នាំ២០១៦)។

ព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងចំនួនរឿងក្តីរបស់ អ.វ.ត.ក. ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ (http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-eccc-caseload)។

[6] នៅក្នុងករណីដែលសំណុំរឿង០០២ ត្រូវបានបំបែកបន្ថែមទៀតតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទៅលើវិសាលភាពនៃសំណុំរឿង០០២/០២ ដែលរំពឹងថានឹងចេញនៅខែមេសា ឆ្នាំ២០១៤ វានឹងតម្រូវឲ្យមានសំណុំរឿង០០២/០៣។

[7] ដូចដែលកត់សម្គាល់ត្រង់កថាខណ្ឌទី៣៦ ខាងក្រោម ដោយសារស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករណ៍នូវចំណុចពេលវេលាជាក់លាក់ ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។ នៅក្នុងករណីដែលរឿងក្តី០០៣ និង០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ គ្រោងការនៃសវនាការលើអង្គសេចក្តីគឺអាចដូចទៅនឹងប្រការដែលមានចែងនៅក្នុងកថាខណ្ឌទី១២(v) រហូតដល់ (x) ខាងលើ ទាក់ទិននឹងសំណុំរឿង០០២/០២។

(xiii) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះ

ស្រាយក្នុងសំណុំរឿង០០៣ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទីមួយ ឆ្នាំ២០១៧ សម្រាប់សំណុំរឿង០០៣)។ និង

(xiv) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ណាមួយ ប្រឆាំងនឹងដីកាដំណោះស្រាយណាមួយ (ណាខ្លះ) ក្នុងសំណុំរឿង០០៤ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទី២ ឆ្នាំ២០១៧)។

## II. វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស

១៥. ដំណើរការប្រកបដោយប្រសិទ្ធភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ កន្លងទៅត្រូវបានរំខានដោយអសន្តិសុខផ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្តាលឲ្យបុគ្គលិកចំនួនពីររូបបានបោះបង់ការងារក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ ការអនុម័តរបស់មហាសន្និបាតទៅលើឧបត្ថម្ភធនចំនួន ១៥,៥ លានដុល្លារអាមេរិក សម្រាប់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកាសម្រាប់ឆ្នាំ២០១៤ និងធ្វើឲ្យមានការផ្តោតមូលទៅលើការធ្វើឲ្យវិវត្តទៅមុខនៃអាណត្តិតុលាការ[8]។ នៅជិតការបិទបញ្ចប់រយៈពេលរបាយការណ៍បច្ចុប្បន្ន នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ មហាសន្និបាតអង្គការសហប្រជាជាតិ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលេខ ៦៩/២៧៤ បានអនុញ្ញាតឲ្យអគ្គលេខាធិការសន្យាជាផ្លូវការក្នុងការផ្តល់ថវិកាចំនួន ១២.១ លានដុល្លារអាមេរិក ដើម្បីបន្ថែមទៅលើធនធានហិរញ្ញវត្ថុស្ម័គ្រចិត្តរបស់ភាគីអន្តរជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញសម្រាប់ឆ្នាំ២០១៥ ដែលនឹងផ្តល់នូវស្ថិរភាពប្រហាក់ប្រហែលគ្នានៅឆ្នាំខាងមុខ ជាមួយនឹងការផ្តល់វិភាគទានស្ម័គ្រចិត្ត និងការគាំទ្រពីប្រទេសផ្តល់ជំនួយ។ ដោយទទួលស្គាល់នូវដំណាក់កាលដែលមានបន្ទុកការងារខ្ពស់បំផុតនៅក្នុងកិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញ និងការពាក់ព័ន្ធទៅនឹងការយកចិត្តទុកដាក់លើធនធាននោះ ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗក៏បានអនុម័តទៅលើគម្រោងថវិកាកែសម្រួលថ្មី សម្រាប់ឆ្នាំ២០១៥ ដែលរួមបញ្ចូលនូវធនធានថ្មីៗទៅលើវិស័យសំខាន់ៗជាច្រើន។ ទិដ្ឋភាពដ៏វិជ្ជមានមួយ គឺការបង្កើនវិភាគទានពីរាជរដ្ឋាភិបាលកម្ពុជា ដែលចំណាយទៅលើប្រាក់ខែបុគ្គលិកជាតិសម្រាប់ប្រាំមួយខែដំបូងនៃឆ្នាំ២០១៥។ បច្ចុប្បន្នវាជាការសំខាន់ដែលត្រូវមានការកៀរគរថវិការបន្ថែម ដើម្បីធ្វើឱ្យមានស្ថិរភាពដល់អង្គជំនុំជម្រះវិសាមញ្ញ សម្រាឆ្នាំ២០១៥ ទាំងមូល។

១៦. ការប៉ាន់ស្មានលើតារាងកំណត់ពេលវេលាខាងក្រោម ត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានថាអង្គជំនុំជម្រះ និងការិយាល័យទាំងអស់មានបុគ្គលិកគ្រប់គ្រាន់ និងថាកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ នឹងមិនត្រូវរំខានបន្ថែមទៀតដោយសារតែអសន្តិសុខផ្នែកហិរញ្ញវត្ថុ។ ប្រសិនបើអសន្តិសុខផ្នែកហិរញ្ញវត្ថុលេចឡើង យើងអាចចាំបាច់ត្រូវកែសម្រួលតារាងពេលវេលាឡើងវិញ។

១៧. ការប៉ាន់ស្មាននានាលើគម្រោងបញ្ចប់ផែនការជំនុំជម្រះក្តីក្នុងសំណុំរឿង០០២/០២ បណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១ និងការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ សន្មត់ថាសកម្មភាពទាំងអស់ កំពុងត្រូវបានធ្វើឡើងដំណាលៗគ្នា។ ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ក៏ដូចជាសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី នឹងចូលពាក់ព័ន្ធទាំងបណ្តឹងសាទុក្ខសំណុំរឿង០០២/០១ និង ការជំនុំជម្រះក្តីសំណុំរឿង០០២/០២ នៅពេលទន្ទឹមគ្នា។ សហព្រះរាជអាជ្ញានឹងចូលរួមក្នុងពេលជាមួយគ្នានៅក្នុងរឿងក្តីទាំងពីរនេះ ក្នុងចំណោមរឿងក្តីទាំងអស់ ព្រមទាំងការស៊ើបអង្កេត និង ការរៀបចំសារណាបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០៣ និង ០០៤។ ការិយាល័យសហព្រះរាជអាជ្ញាបានស្នើសុំធនធានបន្ថែមនៅក្នុងខ្ទង់ថវិកាឆ្នាំ២០១៥ ដែលមានការកែប្រែ ដើម្បីធានាឲ្យប្រាកដថា ការិយាល័យសហព្រះរាជអាជ្ញាមានស្ថិរភាពក្នុងការ

---

[8] សេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៦៨/២៤៧B។

បំពេញភារកិច្ចរបស់ខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០១ សំណុំរឿង០០២/០២ សំណុំរឿង ០០៣ និងសំណុំរឿង០០៤។

១៨. នៅខែមករា ឆ្នាំ២០១៥ កិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក. បានអនុម័តវិសោធនកម្មទៅលើវិធានផ្ទៃក្នុង ដែលអនុញ្ញាតឱ្យមានការកាត់បន្ថយទៅលើវិសាលភាពកិច្ចស៊ើបសួរ លុះត្រាណាវិសាលភាពស៊ើបអង្កេតដែលបានកាត់បន្ថយជាតំណាងឱ្យបទចោទ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យតាមការចោទប្រកាន់។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងអាចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះក្ដីដោយមិនរួមបញ្ចូលអង្គហេតុជាក់លាក់មួយចំនួនដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វិសោធនកម្មទាំងនេះ ប្រសិនបើអនុវត្តបាន គឺអាចពន្លឿនការបញ្ចប់កិច្ចនីតិវិធីស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្តវាយតម្លៃទៅលើថាតើវិធានថ្មីទាំងនេះអាចយកមកអនុវត្ត ដើម្បីពង្រួញវិសាលភាពនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ ដែរ ឬយ៉ាងណា។

១៩. ក្នុងគោលបំណងបង្កើនសមត្ថភាពស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្រសួងយុត្តិធម៌បានផ្ដល់នីតិសម្បទាដល់មន្ត្រីច្បាប់អន្តរជាតិចំនួនប្រាំបួននាក់ ដើម្បីចុះធ្វើកំណត់ហេតុស្ដាប់ចម្លើយ ហើយកិច្ចការនេះជាធម្មតាគឺត្រូវបំពេញដោយអ្នកស៊ើបអង្កេតប៉ុណ្ណោះ។ ការបង្កើនសមត្ថភាពក្នុងការចុះធ្វើកំណត់ហេតុស្ដាប់ចម្លើយនេះ នឹងជំរុញឱ្យដំណាក់កាលស៊ើបសួរបានលឿន។ ជាងនេះទៀតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចាប់អនុវត្តគំនិតផ្ដួចផ្ដើមនានា ដើម្បីបង្កើនធនធានមនុស្សរបស់ខ្លួនជាមួយនឹងបុគ្គលិកជំនាញក្រោមកម្មវិធីដែលមិនត្រូវសងវិញ និងកម្មសិក្សាការីបន្ថែមទៀត ដើម្បីបង្កើនផលិតភាពនៃកិច្ចស៊ើបសួរ។ សមត្ថភាពបំពេញកិច្ចស៊ើបសួរត្រូវបានបង្កើនថែមទៀត នៅពេលដែលអ្នកស៊ើបអង្កេតអន្តរជាតិថ្មីបីរូបបានចូលបម្រើការងារនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងត្រីមាសទី១ ឆ្នាំ២០១៥ ហើយអ្នកស៊ើបអង្កេតអន្តរជាតិថ្មីបីរូបនេះបំពេញកិច្ចការក្នុងរយៈពេលបណ្ដោះអាសន្នតែប៉ុណ្ណោះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្តទាក់ទងរដ្ឋជាសមាជិក និងអង្គការវិជ្ជាជីវៈនានាក្នុងគោលបំណងជ្រើសរើសអ្នកស៊ើបអង្កេតបន្ថែមមកបំពេញការងារជាបុគ្គលិកមិនយកប្រាក់កម្រៃ។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

២០. តារាងកំណត់ពេលវេលានៃការបញ្ចប់ការស៊ើបអង្កេត ត្រូវបានកំណត់ដោយកត្តានានាដូចជា៖ ប្រភេទ និងភាពស្មុគស្មាញនៃរឿងក្ដី ចំនួនសាក្សីដែលត្រូវស្ដាប់សក្ខីកម្ម ចំនួនបេសកកម្មចុះដល់ទីកន្លែងដែលតម្រូវឱ្យមាន លទ្ធភាពមានបុគ្គលិកមានគុណវុឌ្ឍិ និងសមត្ថភាពក្នុងការរក្សាទុកបុគ្គលិកដែលមានបទពិសោធន៍ ឧបសគ្គជាក់ស្ដែងនិងឧបសគ្គធនធានសម្ភារៈក្នុងការបំពេញកិច្ចស៊ើបសួរ ចំនួនញត្តិដែលដាក់ដោយភាគីនានា ថិរវេលាដែលតម្រូវដោយអង្គបុរេជំនុំជម្រះដើម្បីចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្ហើរបស់ភាគីនានា និងការពិចារណាពាក់ព័ន្ធនានា។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការ អាចផ្អែកលើបទពិសោធន៍កន្លងទៅទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងក្នុងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នានេះ។

២១. វិធានផ្ទៃក្នុងដាក់បញ្ញត្តិអំពីដំណាក់កាលនីតិវិធីផ្សេងៗ ដែលសហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តតាម ដើម្បីបំពេញឱ្យបានពេញលេញនូវដំណើរការស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតត្រូវស៊ើបអង្កេតអង្គហេតុនានាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលដាក់ដោយសហព្រះរាជអាជ្ញា។ នៅពេលបំពេញកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចនឹងបំពេញកិច្ចស៊ើបសួរ ដែលនាំឱ្យបញ្ជាក់នូវការពិត។ នៅគ្រប់ករណីទាំងអស់ ពួកគេត្រូវបំពេញកិច្ចស៊ើបសួរដោយអនាគតិ ភាគីនានាអាចស្នើសុំសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរជាក់លាក់មួយចំនួន។ ការបដិសេធមិនពិចារណាលើសំណើសុំ អាចនឹងត្រូវបានប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ បុគ្គលទាំងឡាយដែលត្រូវបានចោទប្រកាន់ ក្នុងនាមជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី គឺបច្ចុប្បន្ននេះមានសិទ្ធិចូលពិនិត្យមើលសំណុំ

រឿងតាមរយៈមេធាវីរបស់ពួកគេ។ ប្រការនេះនឹងអនុញ្ញាតឲ្យពួកគេចូលរួមនៅក្នុងកិច្ចស៊ើបសួរតាមរយៈការធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរ ក៏ដូចជាតវ៉ានឹងដីកា និងសេចក្ដីសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត។ ក្រុមមេធាវីការពារក្ដីនៃជនត្រូវចោទទាំងបីនាក់ នឹងត្រូវផ្ដល់នូវពេលវេលាសមរម្យនៅក្នុងអំឡុងត្រីមាសទី១ ឆ្នាំ ២០១៥ ក្នុងការពិនិត្យសំណុំរឿង ដែលស្របទៅនឹងតម្រូវការនៃដំណើរការត្រឹមត្រូវ និងស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ។

២២. នៅពេលសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ការស៊ើបអង្កេតត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់ភាគីទាំងអស់។ ភាគីមានរយៈពេល១៥ថ្ងៃដើម្បីស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម លើកលែងតែភាគីបោះបង់រយៈពេលនោះចោល។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធចោលសំណើបែបនេះ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសម្រេចមួយ ដែលមានសំអាងហេតុ។ នៅក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ ភាគីទាំងអស់អាចដាក់បណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ នៅពេលដែលរយៈពេលនេះបានផុតកំណត់ ត្រូវបានបោះបង់ចោល ឬបណ្ដឹងឧទ្ធរណ៍ដែលបានលើកឡើងខាងលើត្រូវបានជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងភ្លាមៗទៅឲ្យសហព្រះរាជអាជ្ញា ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ។ សហព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ និង បង្វិលសំណុំរឿងឲ្យសហចៅក្រមស៊ើបអង្កេត នៅក្នុងរយៈពេល ៤៥ ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវបានឃុំខ្លួន និងរយៈពេល ៣ ខែ នៅក្នុងរឿងក្ដីផ្សេងទៀត។ លើកលែងតែក្រោយពេលដំណាក់កាល ដែលលើកឡើងខាងលើនេះត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតនិងចេញដីកាដំណោះស្រាយ ថាតើត្រូវចោទប្រកាន់ជនត្រូវចោទ ដែលត្រូវបញ្ជូនរូបគាត់ទៅជំនុំជម្រះ ឬត្រូវទម្លាក់ចោលការចោទប្រកាន់។ សហព្រះរាជអាជ្ញាអាចនឹងដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទៅអង្គបុរេជំនុំជម្រះ ចំណែកឯដើមបណ្ដឹងរដ្ឋប្បវេណីអាចដាក់បណ្ដឹងឧទ្ធរណ៍ តែក្នុងករណីដីកាដំណោះស្រាយបដិសេធចោលការចោទប្រកាន់ និងក្នុងករណីដែលសហព្រះរាជអាជ្ញាបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធចោលការចោទប្រកាន់នេះ។ បន្ថែមពីលើនេះ អង្គបុរេជំនុំជម្រះបានផ្ដល់នូវសិទ្ធិឲ្យជនត្រូវចោទជំទាស់នឹងធាតុផ្សំយុត្តាធិការនៅក្នុងដីកាដំណោះស្រាយតាមរយៈបណ្ដឹងឧទ្ធរណ៍។ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវតែដាក់នៅក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ។ អង្គបុរេជំនុំជម្រះអាចនឹងកែប្រែ ឬតម្កល់ដីកាដំណោះស្រាយនេះ។

២៣. កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ បានចាប់ផ្ដើមដំណើរការក្រោយពីការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅខែកញ្ញា ឆ្នាំ២០០៩។ ដោយអនុលោមតាមវិធានផ្ទៃក្នុង អ.វ.ត.ក. សហចៅក្រមស៊ើបអង្កេតបានធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿងទាំងនេះ ហេតុដូចនេះ សហចៅក្រមស៊ើបអង្កេតទាំងពីររូបកំពុងតែជ្រើសរើសវិធីសាស្ត្ររៀងៗខ្លួននៅក្នុងសំណុំរឿងទាំងនេះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងតែស៊ើបអង្កេតយ៉ាងសកម្មលើការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅមូលដ្ឋានបទល្មើសចំនួនជាង១០ ផ្សេងៗពីគ្នាក្នុងសំណុំរឿង០០៣ និងមូលដ្ឋានបទល្មើសចំនួន ៥៥ ក្នុងសំណុំរឿង ០០៤។ ចាប់តាំងពីសហចៅក្រមអន្តរជាតិបច្ចុប្បន្ន ចាប់ផ្ដើមបំពេញភារកិច្ចនៅខែតុលា ឆ្នាំ ២០១២ មក មានការបំពេញបេសកកម្មដល់ទីកន្លែងកើតហេតុចំនួនជាង ១០៥ លើក និងធ្វើកិច្ចសម្ភាសន៍ជាមួយសាក្សីបានចំនួនជាង ៥៦៣ នាក់។

២៤. កត្តាជាច្រើនចាំបាច់តម្រូវឱ្យធ្វើការកែប្រែតារាងកំណត់ពេលវេលាសម្រាប់សំណុំរឿង ០០៣ និង ០០៤។ ដើមឡើយវាមានសារៈសំខាន់ក្នុងការរំលឹកឡើងវិញថា ចំនួនទីតាំងឧក្រិដ្ឋកម្ម និងសេណារីយ៉ូស្ថិតក្រោមការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង ០០៤ មានចំនួនច្រើនទ្វេដងនៃអ្វីដែលត្រូវបានស៊ើបអង្កេតក្នុងសំណុំរឿង ០០២ ខណៈដែលចំនួនអ្នកស៊ើបអង្កេត និងមន្ត្រីច្បាប់មានចំនួនតិចជាងពាក់កណ្ដាល ធ្វើការក្នុងសំណុំរឿង

០០៣ និង ០០៤។ ជាងនេះទៀត វិសាលភាពនៃការស៊ើបអង្កេតបានពង្រីក តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនពីរ ដែលបានដាក់ដោយការិយាល័យសហព្រះរាជអាជ្ញា ក្នុងឆ្នាំ២០១៤។

២៥. ការចាកចេញដោយមិនមានការព្រាងទុករបស់បុគ្គលសំខាន់ៗ នៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត បានប៉ះពាល់ខ្លាំងដល់ការរីកចម្រើននៃរឿងក្តី។ ឧទាហរណ៍មួយដ៏ជាក់ស្តែងនោះគឺ ការចាកចេញនៃក្រុមស៊ើបអង្កេតមួយទាំងមូល ដែលមានអ្នកវិភាគម្នាក់ អ្នកស៊ើបអង្កេតម្នាក់ និងមន្ត្រីច្បាប់ម្នាក់ បានពន្យារពេលការស៊ើបអង្កេតពាក់ព័ន្ធទៅនឹងជនសង្ស័យម្នាក់ និងទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធយ៉ាងហោចណាស់ចំនួន ៥ ខែ។ បន្ថែមលើរយៈពេលវែងដែលត្រូវការដើម្បីធ្វើការកំណត់ និងជ្រើសរើសបុគ្គលិកមកជំនួស វាចំណាយពេលតិចបំផុតពី ២ ទៅ ៣ ខែ ដើម្បីឱ្យបុគ្គលិកថ្មីធ្វើការស្វែងយល់រឿងក្តីឱ្យបានគ្រប់គ្រាន់ មុនពេលពួកគេអាចបំពេញតួនាទីបានពេញលេញ។

២៦. កត្តាដែលប៉ះពាល់ដល់ល្បឿននៃការស៊ើបអង្កេតផងដែរនោះគឺការបកប្រែឯកសារមិនទាន់ពេលវេលា និងការពន្យារពេលស្តាប់ចម្លើយសាក្សី ដោយសារកង្វះការបកប្រែភាសាផ្ទាល់មាត់ និង ធនធានគាំទ្រផ្សេងទៀត ក្រោយពីការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ (សូមមើល ស្ថិតិខាងក្រោមក្នុងកថាខណ្ឌ ២៨)។ ពេលមួយក្នុងឆ្នាំ២០១៤ កំណត់ហេតុស្តាប់ចម្លើយសាក្សីសរុបចំនួន ៨.៧០៥ ទំព័រមិនមានការបកប្រែ ហេតុនេះបានពន្យារពេលដល់សមត្ថភាពក្នុងការវិភាគ និងដំណើរការភ័ស្តុតាង។ បន្ទុកការងារដែលមិនទាន់បានបំពេញនេះត្រូវបានដោះស្រាយតាមរយៈការជួលបុគ្គលិកប្រឹក្សាម្នាក់ និងការបង្កើនការកំណត់អាទិភាពសំណើសុំបកប្រែ ដោយអង្គភាពបកប្រែភាសា។ ធនធានបន្ថែមក៏ត្រូវបានផ្តល់ឱ្យអង្គភាពបកប្រែភាសានៅក្នុងគម្រោងថវិកាដែលបានកែប្រែសម្រាប់ឆ្នាំ២០១៥ ដើម្បីបំពេញតម្រូវការសេវាកម្មបកប្រែភាសាទាន់ពេលវេលា[9]។

២៧. កត្តាខាងក្រៅក៏បានរួមចំណែកដល់ការពន្យារពេលកិច្ចស៊ើបសួរផងដែរ។ ការខកខានរបស់ជនសង្ស័យក្នុងការឆ្លើយតបទៅនឹងដីកាកោះ និងអង្គហេតុដែលថាដីកាបង្គាប់ឱ្យនាំខ្លួនមិនត្រូវបានអនុវត្ត បានបណ្តាលឱ្យមានការពន្យារពេលដល់ទៅ ៦,៥ ខែ ក្នុងការផ្តល់សិទ្ធិឱ្យជនសង្ស័យម្នាក់ចូលពិនិត្យសំណុំរឿង។ ការចូលពិនិត្យសំណុំរឿងនេះមានសារៈសំខាន់ខ្លាំង ចំពោះបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក.។ ការចូលពិនិត្យសំណុំរឿង បានអនុញ្ញាតផ្តល់ឱ្យតែជនសង្ស័យចំនួនពីររូបប៉ុណ្ណោះក្នុងខែមីនា ឆ្នាំ២០១៥ បន្ទាប់ពីពួកគេត្រូវបានចោទប្រកាន់កំបាំងមុខ។ បន្ទាប់ពីជនសង្ស័យត្រូវបានចោទប្រកាន់ វិធានទាក់ទងនឹងជនត្រូវចោទត្រូវអនុវត្ត។ វិធានទាំងនេះបង្កើតថិរវេលាសម្រាប់ដំណាក់កាលជាច្រើននៃដំណើរការកិច្ចស៊ើបសួរ និងផ្តល់សិទ្ធិប្តឹងឧទ្ធរណ៍ទៅឱ្យភាគី។ ហេតុដូច្នេះ វិធានជាធរមាន ដែលជាលទ្ធផលនៃការផ្លាស់ប្តូរឋានៈពីជនសង្ស័យទៅជាជនត្រូវចោទ បានធ្វើឱ្យមានការប្រែប្រួលដល់ការព្យាករតារាងកំណត់ពេលវេលាពីមុន។

២៨. សាក្សីជាច្រើនមានមានវ័យចាស់ជរាខ្លាំង ហើយកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួនត្រូវលុបចោល ដោយសារសាក្សីបានស្លាប់ ឬមានសុខភាពទ្រុឌទ្រោម។ នៅពេលដែលចំនួនការស្តាប់ចម្លើយសាក្សីត្រូវបានលុបចោលដោយសារបញ្ហាសុខភាព ឬជំងឺ ត្រូវបានរួមបញ្ចូលជាមួយនឹងចំនួនដែលត្រូវបានលុបចោល

[9] បច្ចុប្បន្ននេះកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ១១ ទំព័រ មិនទាន់ត្រូវបានបកប្រែ ហើយកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ៥២២ ទំព័របានបកប្រែហើយ តែមិនទាន់បានពិនិត្យផ្ទៀងផ្ទាត់។ អង្គភាពបកប្រែភាសាពេលនេះមានលទ្ធភាពដោះស្រាយទាន់ពេលវេលានូវសំណើសុំបកប្រែកំណត់ហេតុស្តាប់ចម្លើយសាក្សីនាពេលខាងមុខ។ ការបកប្រែឯកសារផ្សេងទៀតត្រូវរៀបចំផ្អែកតាមអាទិភាពប្រចាំសប្តាហ៍ ពីការិយាល័យសហចៅក្រមស៊ើបអង្កេត។

ដោយសារបញ្ហាមិនមានធនធានដែលត្រូវការដើម្បីគាំទ្រដល់ការស្តាប់ចម្លើយ អាត្រានៃការលុបចោលនោះមានចំនួន ៣៨ ភាគរយ[10]។

២៩. កត្តាមួយផ្សេងទៀតដែលរារាំងដល់ការរីកចម្រើននៃការស៊ើបអង្កេតនោះគឺ ការបន្តខ្វះកិច្ចសហការពីសំណាក់ប្រទេសមួយចំនួន ក្នុងការផ្តល់សិទ្ធិចូលប្រើប្រាស់បណ្ណសារ និងសម្ភារៈបណ្ណសារ បើទោះបីជាអង្គហេតុដែលថាសំណើសុំទាំងនេះត្រូវបានរង់ចាំតាំងពីឆ្នាំ២០១៣។ សំណើសុំសម្ភារៈទាំងអស់នោះកំពុងត្រូវបានធ្វើឡើង។

៣០. ការព្យាករពេលវេលាដ៏ល្អបំផុត ដែលអាចផ្តល់ជូននាពេលនេះគឺដូចខាងក្រោម៖

(i) ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ នឹងត្រូវបិទបញ្ចប់ត្រឹមត្រីមាសទីបួនក្នុងឆ្នាំ២០១៥។

(ii) ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ អាស្រ័យលើថាតើសំណុំរឿងនឹងត្រូវបំបែកឬអត់ នឹងបិទបញ្ចប់ត្រឹមត្រីមាសទីបួន ឆ្នាំ២០១៥ និង/ឬ ត្រីមាសទីមួយ ឆ្នាំ២០១៦។

(iii) ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ នឹងចេញត្រឹមត្រីមាសទីបី ឆ្នាំ២០១៦។

(iv) ដីកាដំណោះស្រាយមួយ(ច្រើន) ក្នុងសំណុំរឿង ០០៤ អាស្រ័យលើថាតើសំណុំរឿងនឹងត្រូវបំបែកឬអត់ នឹងចេញត្រឹមត្រីមាសទីមួយ ទីបី ឬទីបួន ក្នុងឆ្នាំ២០១៦។

(v) បណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយ នឹងត្រូវសម្រេចដោយអង្គបុរេជំនុំជម្រះត្រឹមត្រីមាសទីមួយ ក្នុងឆ្នាំ២០១៧ សម្រាប់សំណុំរឿង ០០៣ និងត្រីមាសទីពីរក្នុងឆ្នាំ២០១៧ សម្រាប់សំណុំរឿង ០០៤។

## IV. ផែនការបញ្ចប់សវនាការ

៣២. តារាងពេលវេលានៃការបញ្ចប់សវនាការត្រូវកំណត់ដោយកត្តានានាដូចជា លក្ខណៈ និងភាពស្មុគស្មាញនៃសំណុំរឿង បញ្ហាសុខភាពរបស់ជនជាប់ចោទដែលមានវ័យចាស់ជរា ចំនួនសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅ និងរយៈពេលនៃការធ្វើសក្ខីកម្មរបស់សាក្សីទាំងនោះ ការបង្អាក់ជាក់ស្តែងនានាក្នុងការបំពេញកិច្ចដំណើរការនីតិវិធី ចំនួនញត្តិដាក់ដោយភាគី និងការពិនិត្យពិច័យផ្នែករដ្ឋបាលផ្សេងៗទៀត។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការ គឺផ្អែកលើបទពិសោធន៍កន្លងទៅ ទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នា។

២៦. ការប្រជុំរៀបចំសវនាការចំនួនមួយ ឬច្រើន តែងតែបានរៀបចំឡើងមុនពេលការចាប់ផ្តើមសវនាការជាក់ស្តែង។ សវនាការចាប់ផ្តើមដោយសវនាការបឋម។ នៅក្នុងសវនាការបឋមនេះ អង្គជំនុំជម្រះសាលាដំបូង ពិចារណាទៅលើបញ្ជីសាក្សីសក្តានុពល និងអ្នកជំនាញ ដែលដាក់ជូនដោយភាគី ព្រមទាំងអញ្ញត្រកម្មលើកឡើងដោយភាគី ហើយភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តួចផ្តើមនូវចំណុចជាក់លាក់អំពីសំណងដែលខ្លួនស្នើសុំ។ សវនាការលើអង្គសេចក្តីចាប់ផ្តើមដោយមានការធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបពីសំណាក់សហព្រះរាជអាជ្ញា ហើយជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន មុនពេលអង្គជំនុំជម្រះសាលាដំបូង ចាប់ផ្តើមតាំងសំណួរដល់ជនជាប់ចោទ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី និងស្តាប់នូវការបង្ហាញភស្តុតាង។

---

[10] ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ៥៥ ដែលមានផែនការធ្វើឡើងនៅក្នុងអគារអង្គជំនុំជម្រះវិសាមញ្ញ ក្នុងរយៈពេលថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ ការស្តាប់ចម្លើយចំនួន ៥ (៩ ភាគរយ) ត្រូវបានលុបចោល ឬលើកពេល ដោយសារតែសាក្សីឈឺ ការស្តាប់ចម្លើយចំនួន ៦ (១១ ភាគរយ) ត្រូវបានលុបចោល ដោយសារតែសាក្សីទទួលមរណភាព ការស្តាប់ចម្លើយចំនួន ៥ ត្រូវបានលុបចោល ឬលើកពេល ដោយសារតែខ្វះអ្នកបកប្រែភាសាផ្ទាល់មាត់ ឬការគាំទ្រផ្នែកភស្តុភារផ្សេងទៀត (៩ ភាគរយ) និង ការស្តាប់ចម្លើយចំនួន ៥ (៩ ភាគរយ) ត្រូវបានលុបចោល ដោយមូលហេតុផ្សេងៗ។

សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទអង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ក្រោយពេលពិនិត្យភ័ស្តុតាងទាំងអស់រួចហើយ អង្គជំនុំជម្រះស្តាប់ការបិទកិច្ចពិភាក្សាដេញដោលពីសំណាក់ភាគី មុនពេលពិភាក្សាគ្នាជាសម្ងាត់ដើម្បីសម្រេចសេចក្តី។ ប្រសិនបើជនជាប់ចោទត្រូវផ្តន្ទាទោស អង្គជំនុំជម្រះសម្រេចទៅលើទោសសមស្របដែលបានកំណត់នៅក្នុងសាលក្រមរបស់ខ្លួន។ ដោយឈរលើមូលដ្ឋាននៃជំហាននីតិវិធីទាំងនេះទើបយើងកំណត់បាននូវគ្រោងការសំខាន់ៗផ្សេងៗគ្នាសម្រាប់សវនាការនីមួយៗបាន។

## ក. សំណុំរឿង០០២/០២

៣៤. នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញនូវសេចក្តីសម្រេចបំបែកសំណុំរឿងថ្មីមួយទៀត ដោយកំណត់វិសាលភាពក្នុងសំណុំរឿង០០២/០២ ដែលជាការជំនុំជម្រះក្តីវគ្គទីពីរប្រឆាំងនឹង ខៀវ សំផន និង នួន ជា។ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ទីតាំងបទល្មើសដែលបានចោទប្រកាន់ និងការចោទប្រកាន់តាមអង្គហេតុបង្កើតបានជាមូលដ្ឋាននៃសំណុំរឿង០០២/០២៖ អំពើប្រល័យពូជសាសន៍លើជនជាតិចាម និងជនជាតិវៀតណាម (មិនរាប់បញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជា នៅលើទឹកដីវៀតណាម) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ (ទូទាំងប្រទេស) ការបោសសម្អាតផ្ទៃក្នុង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល ការដ្ឋានទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម សហករណ៍នៅត្រាំកក់ ការប្រព្រឹត្តមកលើពុទ្ធសាសនិក (កម្រិតត្រឹមតែសហករណ៍ត្រាំកក់) និងការប្រព្រឹត្តមកលើអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ (ការអនុវត្តកម្រិតត្រឹមតែសហករណ៍ត្រាំកក់ ការដ្ឋានទំនប់១មករា មន្ទីសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់)[11]។ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ អង្គជំនុំជម្រះតុលាការកំពូល តម្កល់សេចក្តីសម្រេចបំបែកសំណុំរឿងថ្មីនេះ។

៣៥. អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការបឋមបន្ថែមទៀតក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤។ នៅក្នុងសវនាការនោះ អង្គជំនុំជម្រះសាលាដំបូង ស្តាប់សារណារបស់ភាគីទៅលើលំដាប់លំដោយនៃនីតិវិធីជំនុំជម្រះបន្ថែមទៅលើសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួនលើវិសាលភាពនៃសំណុំរឿង០០២/០២ ហើយនិងសំណើរបស់ភាគីទាក់ទងនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវស្តាប់សក្ខីកម្ម។ អង្គជំនុំជម្រះក៏បានផ្តល់ឱកាសដល់ដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញនូវបញ្ហាកាន់តែជាក់លាក់ថែមទៀតទៅលើសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។

៣៦. នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ។ បន្ទាប់មក ខៀវ សំផន និង នួន ជា បានបង្ហាញភាពមិនពេញចិត្តក្នុងការចូលរួមក្នុងកិច្ចនីតិវិធី ក្នុងសំណុំរឿង០០២/០២ លុះត្រាតែមានដំណោះស្រាយទៅលើបញ្ហាជាក់លាក់នានា ហើយបានបង្គាប់ឲ្យមេធាវីការពារក្តីរបស់ខ្លួនអនុវត្តទៅតាមការណែនាំរបស់ខ្លួន។ នួន ជា បានចូលរួមសាជាថ្មីនៅក្នុងសំណុំរឿង០០២/០២ នៅថ្ងៃទី១៧ ខែវិច្ឆិកា ចំណែកឯមេធាវីការពារក្តី ខៀវ សំផន បន្តពហិការមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដោយបង្ខំឲ្យអង្គជំនុំជម្រះសាលាដំបូងផ្អាកកិច្ចនីតិវិធីសវនាការលើភ័ស្តុតាងរហូតដល់ ខែមករា ឆ្នាំ២០១៥។

៣៧. កិច្ចដំណើរការនីតិវិធីលើភ័ស្តុតាងបានចាប់ផ្តើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ដោយអង្គជំនុំជម្រះត្រូវធ្វើសវនាការចំនួនបីថ្ងៃក្នុងមួយសប្តាហ៍។ លទ្ធផលនៃការវាយតម្លៃផ្នែកវេជ្ជសាស្ត្ររបស់ជនជាប់ចោទនៅខែមករា ឆ្នាំ២០១៥ បង្ហាញថា ការកំណត់៤ថ្ងៃ ក្នុង១សប្តាហ៍ជាការសមស្រប ដោយសវនាការពេលព្រឹកធ្វើឲ្យបានខ្លីបន្តិច។ ដូច្នេះអង្គជំនុំជម្រះបានត្រឡប់ទៅអនុវត្តតាមពេលកំណត់៤ថ្ងៃក្នុង១សប្តាហ៍វិញ នៅខែ

[11] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមទៀត នៃសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1 ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤។

កុម្ភៈ ដែលជាការពន្លឿនដល់ការជំនុំជម្រះក្តី។ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញសរុបចំនួន២០នាក់ នៅលើប្រធានបទសវនាការលើកទីមួយ ដោយសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញមួយចំនួនទៀតបានគ្រោងផ្តល់សក្ខីកម្ម។ អង្គជំនុំជម្រះក៏បានជូនដំណឹងដល់ភាគីថា សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៨នាក់ នឹងត្រូវស្តាប់សក្ខីកម្មអំពីការដ្ឋានទំនប់១មករា។

៣៨. ចំនួនថ្ងៃសម្រាប់បើកនិងបញ្ចប់សវនាការពេញលេញ គឺអាចស្មានទុកបានក្នុងសំណុំរឿង ០០២/០២ តែនៅពេលចំនួនទូទៅនៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវកោះហៅ មានការកំណត់ច្បាស់លាស់ហើយដោយអង្គជំនុំជម្រះសាលាដំបូង។ សក្ខីកម្មសរុបចំនួន ២៧២ ត្រូវបានស្នើឡើងដោយភាគី។ ការស្មានទុកពេលទាក់ទិននឹងសំណុំរឿង០០២/០២ គឺផ្អែកទៅលើការសន្មតថាសវនាការទីពីរនឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាដូចគ្នានឹងសវនាការ០០២/០១ ដែរ ប៉ុន្តែអាចខុសប្លែកពីគ្នាច្រើន នៅពេលដែលកត្តានេះត្រូវបានកំណត់ពេញលេញ។ បន្ទាប់ពីការបើកសវនាការលើភស្តុតាងជាថ្មី នៅខែមករា ពុំមានសញ្ញាណបញ្ជាក់អំពីការធ្វើពហិការសាជាថ្មីឡើយ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី វាអាចជាការចាំបាច់សម្រាប់អង្គជំនុំជម្រះកែតម្រូវទៅលើការគ្រោងទុកសកម្មភាពសំខាន់ៗ ដើម្បីផ្ទុះបញ្ចាំងជាមួយនឹងការបាត់បង់រយៈពេល ៣ខែទៅលើការពហិការកន្លងទៅ។

៣៩. ចំពោះកត្តានានាដែលអាចទាក់ទិននឹងរយៈពេលនៃការជំនុំជម្រះដែលស្មានទុក ដែលអាចនឹងកើតឡើងនៅថ្ងៃអនាគត ការប្រែប្រួលស្ថានភាពសុខភាពរបស់ជនជាប់ចោទ ដែលធ្វើឱ្យមានតម្រូវការកាត់បន្ថយចំនួនថ្ងៃសវនាការក្នុងមួយសប្តាហ៍ និង/ឬរយៈពេលនៃថ្ងៃមានសវនាការ នឹងមានផលប៉ះពាល់ដោយផ្ទាល់។ នីតិវិធីបណ្តឹងសាទុក្ខ ប្រឆាំងសាលក្រមសំណុំរឿង០០២/០១ ដូចជាសវនាការ ឬសារណាបន្ថែមជាដើម ក៏អាចប៉ះពាល់ថែមទៀតទៅលើវត្តមានរបស់ភាគីក្នុងការចូលរួមសវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង០០២/០២ ដែលកំណត់កាលបរិច្ឆេទដូចគ្នាផងដែរ។ ការកែតម្រូវបែបនេះក៏អាចត្រូវការពិចារណាទៅលើបញ្ហានានាដែលទាក់ទិននឹងការដាក់បង្ហាញឯកសារពីសំណុំរឿង០០៣ និង០០៤ ដែលកំពុងតែដំណើរការផងដែរ។ ក្នុងត្រីមាសមុន ការដាក់បង្ហាញចម្លើយសាក្សីពាក់ព័ន្ធរាប់រយពីការស៊ើបអង្កេតសំណុំរឿង០០៣ និង ០០៤ ដល់ភាគីក្នុងសំណុំរឿង០០២ មកដល់ពេលនេះបានតម្រូវឱ្យអង្គជំនុំជម្រះផ្អាកសវនាការមួយចំនួនពីរសប្តាហ៍។ ការដាក់បង្ហាញឯកសារនេះត្រូវរំពឹងថែមទៀតថានឹងនាំឱ្យមានសំណើពីភាគីសុំស្តាប់សក្ខីកម្មសាក្សីថែមទៀត។ ការដាក់បង្ហាញចម្លើយសាក្សីបន្ថែមនឹងកើតមានឡើង ហើយបើផ្អែកលើទំហំ វានឹងតម្រូវឱ្យមានការលើកពេលបន្ថែមទៀត។

៤០. ដោយហេតុថាការជំនុំជម្រះក្តីស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ ដូច្នេះអង្គជំនុំជម្រះមិនអាចកំណត់បានរយៈពេលដែលចាំបាច់ត្រូវពន្ធាតចំពោះកិច្ចដំណើរការនីតិវិធីក្រោយពីមានពហិការកន្លងទៅ ការដាក់បង្ហាញឯកសារ និង បញ្ហាផ្សេងៗទៀត។ អង្គជំនុំជម្រះគួរតែអាចធ្វើដូច្នេះបាននៅចុងឆ្នាំនេះ។

### ខ. បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុក្នុងសំណុំរឿង០០២

៤១. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ អង្គជំនុំជម្រះតុលាការកំពូលប្រកាសផ្អាកដំណើរការនីតិវិធីពាក់ព័ន្ធនឹងបទចោទដែលនៅសល់ ដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ និង ០០២/០២ ដោយរង់ចាំសេចក្តីសម្រេចសមស្របរបស់អង្គជំនុំជម្រះសាលាដំបូង[12]។ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងម្តងទៀតថា អង្គជំនុំជម្រះសាលាដំបូងមានករណីកិច្ចកាត់សេចក្តី ឬចេញសេចក្តីសម្រេចទៅលើបទចោទដែលនៅសល់ក្នុងសំណុំរឿង០០២ អនុលោមតាមក្រមខណ្ឌគតិយុត្តិ និងជំរុញឱ្យអង្គ

[12] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើការនីតិវិធីបន្ថែមនៃសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1/13 ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤។

ជំនុំជម្រះសាលាដំបូងអនុវត្តទៅតាមករណីកិច្ចនេះ។ មកដល់ពេលនេះ អង្គជំនុំជម្រះពុំទាន់បានទទួលសំណើណាមួយទាក់ទិននឹងបញ្ហានេះទេ។ បញ្ហានេះនៅតែស្ថិតក្នុងការពិចារណាដដែល។

### គ. សំណុំរឿង០០៣ និង សំណុំរឿង០០៤

៤២. លុះត្រាតែមានសេចក្តីសម្រេចថាតើ សំណុំរឿង០០៣ និង/ឬ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ទើបអាចធ្វើការស្មានទុកបានទៅលើរយៈពេលសម្រាប់បញ្ចប់ការជំនុំជម្រះក្តីទាំងនេះបាន។ ការវាយតម្លៃលើពេលវេលាដែលតម្រូវ អាចផ្អែកទៅលើចំនួនចុងចោទ ក៏ដូចជាចំនួន និងភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់នៃបទចោទ និងទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## V. ផែនការបញ្ចប់បណ្តឹងសាទុក្ខ

៤៣. ដើម្បីធ្វើការប៉ាន់ស្មានអំពីរយៈពេលសម្រាប់ដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ត្រូវតែញែកឲ្យបានច្បាស់អំពីដំណាក់កាលបណ្តឹងសាទុក្ខ ដូចតទៅ ៖ ដំណាក់កាលទីមួយ គឺត្រូវការពេលវេលាសម្រាប់ដាក់សារណារបស់ភាគីទាំងអស់។ អនុលោមតាមវិធានផ្ទៃក្នុង ភាគីត្រូវដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុងករណីដែលមានបណ្តឹងសាទុក្ខដោយភាគីណាមួយ ភាគីដទៃទៀតមានរយៈពេលបន្ថែម១៥ថ្ងៃទៀត ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ។ វិធានផ្ទៃក្នុងចែងថាម្ចាស់បណ្តឹងសាទុក្ខត្រូវដាក់ជូនសារណាបណ្តឹងសាទុក្ខក្នុងរយៈពេល ៦០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីការប្តឹងសាទុក្ខ។ ភាគីនឹងមានរយៈពេល១០ថ្ងៃក្នុងការដាក់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ភាគីដទៃទៀត។ ប៉ុន្តែកាលពីពេលកន្លងទៅ អង្គជំនុំជម្រះបានផ្តល់ជូនរយៈពេលបន្ថែមសមរម្យសម្រាប់ដាក់ចម្លើយតប។ ក្នុងអំឡុងពេលនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងស្រាវជ្រាវទៅលើបញ្ហាច្បាប់ និងអង្គហេតុដែលពាក់ព័ន្ធ ដើម្បីរៀបចំខ្លួនពេញលេញសម្រាប់សវនាការលើបណ្តឹងសាទុក្ខ ដែលជាដំណាក់កាលទីពីរ។ សវនាការលើបណ្តឹងសាទុក្ខអាចត្រូវបានបង្គាប់ នៅពេលណាភាគីបានដាក់សារណាទាំងអស់របស់ខ្លួន និងពិនិត្យដោយអង្គជំនុំជម្រះតុលាការកំពូលរួចហើយសិន។ ដំណាក់កាលទីបី គឺការពិភាក្សាសម្រេចក្រោយពេលសវនាការនោះ និងការរៀបចំចេញសាលដីកាលើបណ្តឹងសាទុក្ខ។

### ក. សំណុំរឿង០០២/០១

៤៤. តាមសំណើរបស់ក្រុមមេធាវីការពារក្តីទាំងអស់នេះ អង្គជំនុំជម្រះតុលាការកំពូលបានពន្យារពេលកំណត់ដាក់ការជូនដំណឹងរបស់ក្រុមមេធាវីការពារក្តីអំពីបណ្តឹងសាទុក្ខលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១ ដោយបន្ថែមរយៈពេល ២១ ថ្ងៃ រហូតដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤[13]។ ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួនទាន់ពេល នឹងបានដំឡើងមូលដ្ឋានបណ្តឹងសាទុក្ខរបស់ខ្លួនដល់ទៅ ២២៣ សម្រាប់ នួន ជា និង ១៤៨ សម្រាប់ ខៀវ សំផន ដែលគ្របដណ្តប់លើស្ទើរតែការរកឃើញទាំងអស់ក្នុងសាលក្រមសំណុំរឿង ០០២/០១ ព្រមទាំងលើសេចក្តីសម្រេចជាច្រើនរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនអនុញ្ញាតបើកផ្លូវប្តឹងសាទុក្ខភ្លាមៗ រហូតទាល់តែចេញសាលក្រមលើអង្គសេចក្តី[14]។ លើសនេះទៀត សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដែលកំហិតត្រឹមតែការស្នើសុំការប្រកាសពីអង្គជំនុំជម្រះតុលាការកំពូល ទាក់ទងនឹងភាពអាចអនុវត្ត

---

[13] សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ស្នើសុំការបន្ថែមពេលវេលានិងចំនួនទំព័រកំណត់លើការជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខ ឯកសារ E3/3 ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤។

[14] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/1/1 ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/1/1 ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤។

បាននៃទម្រង់ពង្រីកបំផុតនៃសហឧក្រិដ្ឋកម្មរួម ដែលគេស្គាល់ថា "JCE III" នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ[15]។

៤៥. អនុលោមតាមសំណើពីក្រុមការពារក្តី និងសហព្រះរាជអាជ្ញា នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះតុលាការកំពូល បានអនុញ្ញាតឱ្យក្រុមការពារក្តីដាក់បណ្តឹងសាទុក្ខរបស់ខ្លួន មិនឱ្យលើសពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ពោលគឺ ៩០ថ្ងៃ ក្រោយការជូនដំណឹងអំពីបណ្តឹងសាទុក្ខ ជាភាសាអង់គ្លេស ឬជាភាសាបារាំង។ ហើយសហព្រះរាជអាជ្ញាអាចដាក់ចម្លើយតបរួម មិនលើសពី ២៨០ ទំព័រ ក្នុងរយៈពេល ៣០ ថ្ងៃ នៃការដាក់សារណាបណ្តឹងសាទុក្ខរបស់ក្រុមការពារក្តីជាភាសាខ្មែរ គឺសារណាបណ្តឹងសាទុកមួយណាក៏ដោយដែលជូនដំណឹងក្រោយគេ[16]។ អង្គជំនុំជម្រះតុលាការកំពូលមិនបានផ្តល់ពេលវេលាបន្ថែមឱ្យសហព្រះរាជអាជ្ញា ក្នុងការដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួននោះទេ[17] ដែលត្រូវដាក់ឱ្យទាន់ពេលកំណត់ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០១៤[18]។ បន្ទាប់ពីការស្នើសុំ អង្គជំនុំជម្រះតុលាការកំពូល បានអនុញ្ញាតផ្តល់ជូនចំនួនទំព័របន្ថែម ៦០ ទំព័រ ទៅឱ្យក្រុមការពារក្តី នួន ជា សម្រាប់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន (ក្រុមការពារក្តី ខៀវ សំផន មិនបានស្នើសុំបែបនេះទេ) និងផ្តល់ពេលវេលាបន្ថែមទៅឱ្យក្រុមការពារក្តីទាំងពីរ ក្នុងការដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ចំនួន ៣០ ថ្ងៃ ក្រោយការដាក់សារណាបណ្តឹងសាទុក្ខរបស់ពួកគេ ពោលគឺ មិនលើសពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥[19]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានអនុញ្ញាតផ្តល់ឱ្យតាមសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន តែជាភាសាអង់គ្លេសប៉ុណ្ណោះ[20]។

៤៦. សំណៅបកប្រែភាជាភាសាខ្មែរនៃសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ត្រូវបានជូនដំណឹងនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ដូច្នេះកាលបរិច្ឆេទកំណត់សម្រាប់ចម្លើយតបរបស់សហព្រះរាជអាជ្ញាតបទៅនឹងសារណាបណ្តឹងសាទុក្ខនឹងត្រូវមុនថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥។ កាលបរិច្ឆេទកំណត់សម្រាប់ចម្លើយតបពីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវផុតកំណត់នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០១៥។ គេរំពឹងថា អង្គជំនុំជម្រះតុលាការកំពូលអាចនឹងមានវគ្គសវនាការលើបណ្តឹងសាទុក្ខមួយចំនួន ដោយសារតែភាពស្មុគស្មាញ និងវិសាលភាពនៃបណ្តឹងសាទុក្ខ ហើយសវនាការលើបណ្តឹងសាទុក្ខទាំងនេះ ត្រូវបានគ្រោងចាប់ផ្តើមនៅត្រីមាសទីបី ឆ្នាំ២០១៥ គឺនៅពេលដែលការដាក់ឯកសារទាំងអស់បានបញ្ចប់ និងបន្ទាប់ពីបានទទួលការបកប្រែទាំងអស់។

៤៧. មានការលំបាកក្នុងប៉ាន់ស្មានឱ្យបានត្រឹមត្រូវ ចំពោះរយៈពេលដែលរំពឹងទុកនៃកិច្ចដំណើការនីតិវិធីបណ្តឹងសាទុក្ខ មុនពេលសារណាបណ្តឹងសាទុក្ខត្រូវបានធ្វើឡើងពេញលេញ ដែលគេរំពឹងថាក្នុងត្រីមាសទីពីរ ឆ្នាំ២០១៥។ ហេតុដូច្នេះ ការប៉ាន់ស្មានបច្ចុប្បន្ននេះ ផ្អែកលើការសន្មត់ថា មូលដ្ឋានបណ្តឹងសាទុក្ខទាំងអស់នៅក្នុងសារណាបណ្តឹងសាទុក្ខបានដាក់ រួមបញ្ចូលទាំងបណ្តឹងសាទុក្ខពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនអាចលើកឡើងជាបណ្តឹងសាទុក្ខបន្ទាន់បង្ហ ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីសវនាការទាំង

[15] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/3/1 ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤។
[16] សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប ឯកសារ F9 ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ("សេចក្តីសម្រេចលើការបន្ថែមរយៈពេលនិងចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខ") កថាខណ្ឌ ២៣។
[17] សេចក្តីសម្រេចលើការបន្ថែមរយៈពេលនិងចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខ កថាខណ្ឌ១៤។
[18] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿងលេខ ០០២/០១ ឯកសារ F11 ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤។
[19] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រ ដើម្បីប្តឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប ឯកសារ F13/2 ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤។
[20] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់សារណាតបតែមួយភាសាហើយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ ឯកសារ F21/1 ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥។

នោះ ព្រមទាំងផ្អែកលើញត្តិដាច់ដោយឡែកពីគ្នាបីស្នើសុំភ័ស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ ដែលបានដាក់ដោយក្រុមការពារក្តី នួន ជា តាំងពីពេលចេញសាលក្រមសំណុំរឿង ០០២/០១[21]។ ទោះជាយ៉ាងណា ផលប៉ះពាល់ទាំងស្រុងនៃញត្តិទាំងនេះ មិនអាចត្រូវបានវាយតម្លៃដោយមិនមានទំហំពេញលេញនៃសារណាបណ្តឹងសាទុក្ខបានទេ។

៤៨. កត្តាមួយផ្សេងទៀត ដែលប៉ះពាល់ខ្លាំងលើរយៈពេលនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ គឺស្ថិតនៅលើលទ្ធភាពនៃការបកប្រែភាសា ជាពិសេស ពីភាសាអង់គ្លេសទៅភាសាខ្មែរ។ មកទល់ពេលនេះ ល្បឿននៃការបកប្រែភាសា បាននាំឱ្យមានការពន្យារពេលចាប់ផ្តើមសារណាលើបណ្តឹងសាទុក្ខ ពីត្រីមាសទីពីរទៅត្រីមាសទីបី ឆ្នាំ២០១៥[22]។

៤៩. ដោយពិចារណាលើកត្តាទាំងអស់នេះ និងបទពិសោធន៍ពីតុលាការ និងសាលាក្តីអន្តរជាតិ និង អន្តរជាតូបនីយកម្មផ្សេងទៀត ដែលសំណុំរឿងមានទំហំនិងភាពស្មុគស្មាញប្រហាក់ប្រហែលគ្នា ហេតុនេះ ការប៉ាន់ស្មានល្អបំផុតដែលអាចផ្តល់ជូននាពេលនេះគឺថា ដំណើរការបណ្តឹងសាទុក្ខអាចនឹងត្រូវបញ្ចប់នៅត្រីមាសទីមួយឆ្នាំ២០១៦។ កាន់តែជាក់លាក់ជាងនេះទៀតនោះ ខែបន្ទាប់ៗនឹងពាក់ព័ន្ធទៅនឹងការពិនិត្យការដាក់ឯកសារទាំងអស់ បន្ទាប់មកនឹងមានការរៀបចំនិងការធ្វើសវនាការលើបណ្តឹងសាទុក្ខ។ បន្ទាប់ពីនោះមក អង្គជំនុំជម្រះតុលាការកំពូលនឹងបញ្ចប់ការប្រជុំពិភាក្សា និងរៀបចំចេញសាលដីកាបណ្តឹងសាទុក្ខរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១។

### ខ. សំណុំរឿង ០០២/០២

៥០. សម្រាប់សំណុំរឿង០០២/០២ ដោយផ្អែកលើការព្យាករណ៍បច្ចុប្បន្នរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាការជំនុំជម្រះដំណាក់កាលទីពីរទំនងជានឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាច្រើនដូចជាការជំនុំជម្រះដំណាក់កាលទីមួយនោះ អង្គជំនុំជម្រះតុលាការកំពូលក៏ព្យាករណ៍ស្រដៀងគ្នានេះដែរនៅពេលនេះដែលថាបណ្តឹងសាទុក្ខ(ទាំងឡាយ)ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះក្នុងសំណុំរឿង០០២/០២ នឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាច្រើន ដូចគ្នានឹងបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង០០២/០១ ហើយកត្តានានា ដូចជាសំណើសុំពន្យារពេលក្នុងការដាក់សារណា ឬញត្តិ ដើម្បីស្នើដាក់ជូនភ័ស្តុតាងបន្ថែម អាចប៉ះពាល់ដល់រយៈពេលនៃដំណើរការនីតិវិធីបណ្តឹងសាទុក្ខ។ ទំហំការងារបែបនេះនឹងត្រូវការគិតបញ្ចូលទៅក្នុងការរៀបចំផែនការក្រោយពេលមានការដាក់បណ្តឹងសាទុក្ខ។

៥១. ជាងនេះទៅទៀត បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២ ត្រូវតែសម្រេចក្នុងរយៈពេលបីខែជាកំណត់។ ផ្អែកលើបទពិសោធន៍ពីសំណុំរឿង ០០២/០១ ដែលគិតជាមធ្យមមានបណ្តឹងសាទុក្ខភ្លាមៗចំនួនមួយផងដែរក្នុងមួយខែត្រូវបានដាក់ រំពឹងថានឹងមានបណ្តឹងសាទុក្ខភ្លាមៗជាច្រើនចេញមកពីកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង០០២/០២ ផងដែរ។ ប្រការនេះអាចធ្វើឱ្យមានតម្រូវការធនធានរបស់អង្គជំនុំជម្រះតុលាការកំពូលកាន់តែច្រើនឡើង ហើយប៉ះពាល់ដល់តារាងកំណត់ពេលវេលាសម្រាប់ការចេញសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១។

---

[21] សំណើសុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F2 ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៤។ សំណើទីពីរស្នើសុំឱ្យពិចារណាទៅលើភ័ស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F2/1 ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៤។ សំណើលើកទីបី សុំឱ្យធ្វើការពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទងបណ្តឹងសាទុក្ខប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ឯកសារ F2/4 ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៥ (សម្ងាត់បំផុត)។

[22] សំណៅបកប្រែជាភាសាខ្មែរនៃសារណាបណ្តឹងសាទុក្ខត្រូវបានរំពឹងថានឹងត្រូវជូនដំណឹង នៅចុងខែកុម្ភៈ ឆ្នាំ២០១៥ ប៉ុន្តែការបកប្រែចុងក្រោយជាភាសាខ្មែរ នៃសារណាបណ្តឹងសាទុក្ខ ត្រូវបានជូនដំណឹងនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥។

## VI. សេចក្តីសន្និដ្ឋាន

៥២. សម្រាប់ឆ្នាំ ២០១៥ កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ និង នីតិវិធីជំនុំជម្រះក្តីក្នុងសំណុំរឿង០០២/០២ នឹងបន្តស្របគ្នារហូតពេញមួយឆ្នាំ។ សម្រាប់សំណុំរឿង០០២/០១ រំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួន ២ ថែមទៀតគឺ (i) ការដាក់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខ និង (ii) ការបញ្ចប់សវនាការបណ្តឹងសាទុក្ខ។ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការថ្មីចំនួន ១ ពោលគឺទាក់ទិននឹង សំណុំរឿង០០៣ និង ០០៤ នោះគឺ សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ ក្នុងសំណុំរឿង០០៣។ ជាងនេះទៀត ប្រសិនបើសំណុំរឿង០០៤ ត្រូវបានបំបែក មានការរំពឹងថាសេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿងចំនួន ២ ក្នុងចំណោមសំណុំរឿងចំនួន ៣ ដែលបានបំបែក ក៏អាចនឹងត្រូវចេញនៅចុងឆ្នាំ ២០១៥ នេះផងដែរ។

៥៣. សម្រាប់ឆ្នាំ២០១៦ គេរំពឹងថា គ្រោងការចំនួន ៣ នឹងត្រូវសម្រេចបានក្នុងសំណុំរឿង០០២/០១ និង ០០២/០២ (i) ការចេញសាលក្រមក្នុងសំណុំរឿង០០២/០១ (ii) ការបញ្ចប់សវនាការលើអង្គសេចក្តី/ភ័ស្តុតាងក្នុងសំណុំរឿង០០២/០២ និង (iii) ការចេញសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២។ ចំពោះសំណុំរឿង០០៣ និង ០០៤ មានការរំពឹងថា នឹងសម្រេចបានគ្រោងការចំនួន៣៖ (i) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ជាមួយនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតថាតើត្រូវបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីតែម្តង។ (ii) សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤ និង (iii) ការចេញដីកាដំណោះស្រាយមួយ(ច្រើន)ក្នុងសំណុំរឿង០០៤ ជាមួយនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ថាតើត្រូវបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី។

៥៤. សម្រាប់ឆ្នាំ២០១៧ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួន ២ ក្នុងសំណុំរឿង០០២/០២ ពោលគឺ៖ (i) ការចេញសាលក្រមលើសំណុំរឿង០០២/០២ (ii) កាលបរិច្ឆេទចុងក្រោយក្នុងការដាក់បណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២។ ក្នុងសំណុំរឿង ០០៣ និង ០០៤ រំពឹងថានឹងសម្រេចបានគ្រោងការសំខាន់ចំនួនពីរបន្ថែមទៀតគឺ (i) ការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ និង (ii) ការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ជាមួយនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី។ ក្នុងករណីដែលសំណុំរឿងណាមួយ ឬសំណុំរឿងទាំងពីរ ត្រូវបានបញ្ជូនទៅជំនុំជម្រះទាំងមូល ឬដោយផ្នែក ការព្យាករណ៍ទុកនូវតារាងកំណត់ពេលវេលាក្នុងសំណុំរឿងទាំងនេះគឺអាចយកមកវាយតម្លៃបាន។

៥៥. ក្នុងអំឡុងឆ្នាំ២០១៨ អង្គជំនុំជម្រះតុលាការកំពូលនឹងជាប់រវល់ធ្វើសវនាការបណ្តឹងសាទុក្ខ និងការពិភាក្សាសម្រេច ក្នុងករណីដែលមានបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

៥៦. សម្រាប់ឆ្នាំ២០១៩ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួនមួយ គឺ (i) ការចេញសាលដីកាលើសំណុំរឿង០០២/០២។

៥៧. ការស្មានទុកនូវគ្រោងការនានាដែលរៀបរាប់ខាងលើនេះ មានសង្ខេបជូនក្នុងតារាងដែលភ្ជាប់ជូនជាមួយនឹងផែនការនេះស្រាប់។

# តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានគ្រោងការសំខាន់ៗ

| សំណុំរឿង | | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ |
| សំណុំរឿង ០០២/០១ | បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូង<br>(ក) | (ខ) | | | | | | | | | | | | | | | | | |
| | (គ) | | | | | | | | | | | | | | | | | | |
| (ក) កាលបរិច្ឆេទកំណត់សម្រាប់ចម្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខ<br>(ខ) សវនាការលើបណ្ដឹងសាទុក្ខ<br>(គ) សាលដីកាបណ្ដឹងសាទុក្ខ | | | | | | | | | | | | | | | | | | | |
| សំណុំរឿង ០០២/០២ | ដំណាក់កាលជំនុំជម្រះ | | | | | (ង) | (ច) | | | (ឆ) | (ជ) | បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង | | | | | (ឈ) | | |
| (ង) ការបញ្ចប់សវនាការលើអង្គសេចក្ដី<br>(ច) សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល<br>(ឆ) សាលក្រម<br>(ជ) កាលបរិច្ឆេទកំណត់សម្រាប់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម<br>(ឈ) សាលដីកា | | | | | | | | | | | | | | | | | | | |
| សំណុំរឿង ០០៣ | | | (ញ) | | | (ដ) | បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឋ) | | | | | | | | | | | | |
| (ញ) ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេត<br>(ដ) ដីកាដំណោះស្រាយ កសចស<br>(ឋ) សេចក្ដីសម្រេចរបស់ អបជ ទៅលើដីកាដំណោះស្រាយ | | | | | | | | | | | | | | | | | | | |
| សំណុំរឿង ០០៤ គ្មានការបំបែក | | | | (ឌ) | | | (ឍ) | បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ណ) | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| *សំណុំរឿង ០០៤/០១* | | | (ឌ) | (ឍ) | | (ណ) | | | | | | | | | | | | | |
| *សំណុំរឿង ០០៤/០២* | | | (ឌ) | | | (ឍ) | | ណ) | | | | | | | | | | | |
| *សំណុំរឿង ០០៤/០៣* | | | | (ឌ) | | | (ឍ) | | (ណ) | | | | | | | | | | |

ប្រសិនបើបំបែក

(ឌ) ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេត។ ពេលវេលាកំណត់អាស្រ័យទៅលើថាតើ សំណុំរឿងនឹងត្រូវបានបំបែកឬទេ។

ប្រសិនបើបំបែក

(ឍ) ដីកាដំណោះស្រាយ កសចស។ ពេលវេលាកំណត់អាស្រ័យទៅលើ សំណុំរឿងនឹងត្រូវបានបំបែកឬទេ។

(ណ) សេចក្ដីសម្រេចរបស់ អបជ ទៅលើដីកាដំណោះស្រាយ។

ប្រសិនបើបំបែក